**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ផែនការគ្រប់គ្រងកន្លែងនេសាទ សហគមន៍ក្រើយអូរក្របីខ្វកមានជ័យ

## សម្រាប់រយៈពេល ០៣ ឆ្នាំ
## (ខែសីហា ២០១៧-ខែសីហា ២០២០)

| | |
|---|---|
| សហគមន៍នេសាទ | ៖ក្រើយអូរក្របីខ្វកមានជ័យ |
| ភូមិ | ៖ ក្រើយអូរ |
| ឃុំ | ៖ ព្នៅ |
| ស្រុក | ៖ សន្ទុក |
| ខេត្ត | ៖ កំពង់ធំ |

**ថ្ងៃទី១០ ខែមិថុនា ឆ្នាំ ២០១៧**

# មាតិកា


១.ស្ថានភាពទូទៅ ........................................................................................ ៤
២.អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម.............................................................. ៥
ក.ប្រជាពលរដ្ឋ ........................................................................................ ៥
ខ.សេដ្ឋកិច្ចសង្គម ..................................................................................... ៥
៣.កន្លែងនេសាទ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍.......... ......................... ៦
ក.ទីតាំង.................................................................................................. ៦
ខ. ដែននេសាទ.......................................................................................... ៧
ខ.១.បឹង.................................................................................................. ៧
ខ.២.អូរ.................................................................................................. ៧
គ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស ........................................... ៨
ឃ.ធនធានជលផល...................................................................................... ៨
ឃ.១.ប្រភេទត្រី ........................................................................................ ៨
ឃ.២.ប្រភេទវារីសត្វ ................................................................................... ៨
ឃ.៣.ប្រភេទបក្សី........................................................................................ ៨
ឃ.៤.ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ ................................................... ៨
៤.ការធ្វើនេសាទ......................................................................................... ៩
ក.អ្នកនេសាទ ........................................................................................... ៩
ខ.ឧបករណ៍នេសាទ ..................................................................................... ៩
គ.ប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ ..................................................... ១០
៥.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍...................................................... ១១
ក.ទស្សនៈវិស័យ ........................................................................................ ១១
ខ.គោលបំណង........................................................................................... ១១
គ.១.ផែនការប្រើប្រាស់ឧបករណ៍នេសាទ.......................................................... ១១
គ.២.ផែនការកែលំអដែននេសាទ ................................................................... ១២
គ.៣.ផែនការរៀបចំកន្លែងអភិរក្ស ................................................................. ១៣
គ.៤.ផែនការគ្រប់គ្រងព្រៃលិចទឹក.................................................................. ១៤
គ.៥.ផែនការអភិវឌ្ឍន៍វារីវប្បកម្ម ................................................................... ១៥
គ.៦.ផែនការអភិវឌ្ឍន៍មុខរបរទ្រទ្រង់ជីវភាព ...................................................... ១៦
គ.៧.ផែនការអភិវឌ្ឍន៍កម្មវិធីចំរុះ ................................................................... ១៧
គ.៨.ផែនការពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍នេសាទ.................................. ១៨
គ.៩.ផែនការផ្សព្វផ្សាយពីច្បាប់ជលផល និងលិខិតបទដ្ឋានពាក់ព័ន្ធ ........................... ១៩
គ.១០.ផែនការសាងសង់ស្នាក់ការសហគមន៍នេសាទ ............................................. ២០
គ.១១.ផែនការថវិការទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍......................................... ២០

គ.១២.ផែនការពង្រឹងបណ្ដាញសហគមន៍នេសាទ និងចូលប្រជុំផ្សេងៗ ........................................ ២១
ឃ.យុទ្ធសាស្ត្រ........................................................................................................ ២១
៦.ឧបសម្ពន្ធ
ឧបសម្ពន្ធ ៖តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ឆ្នាំ២០១៧ ដល់ ២០២០
ឧបសម្ពន្ធ ៖ តារាងកម្មវិធីការងារឆ្នាំ២០១៧ ដល់ ២០២០

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ត្រើយអូរក្របីខ្វកមានជ័យ

## ១. ស្ថានភាពទូទៅ

នៅឆ្នាំ២០០០ រដ្ឋបាលជលផល បានធ្វើកំណែទម្រង់ ដើម្បីឲ្យស្របជាមួយគោលនយោបាយវិមជ្ឈការ វិសហមជ្ឈការ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ដែលផ្តោតលើការកាត់បន្ថយភាពក្រីក្រដោយផ្ទេរសិទ្ធិអំណាចដល់ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់ជនបទ ដើម្បីចូលរួមគ្រប់គ្រងធនធានជលផលនៅមូលដ្ឋានរបស់ខ្លួនប្រកបដោយចីរភាព និងសមធម៌តាមបែបសហគមន៍នេសាទ ក្នុងគោលបំណងទទួលផលប្រយោជន៍ និងធ្វើឱ្យធនធានជលផលឱ្យប្រសើរឡើងក្នុងមូលដ្ឋានរបស់ខ្លួន។ កន្លងមកចំនួនភូមិ ០៦ ត្រូវបានរៀបចំសហគមន៍នេសាទដោយមានការចូលរួមយ៉ាងកុះករពីប្រជាពលរដ្ឋមូលដ្ឋាន និងបានការគាំទ្រពីគម្រោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប ជំនាញជលផល និងកិច្ចសហការពីអាជ្ញធរដែនដី ។ ដូចនេះ សហគមន៍នេសាទត្រើយអូរក្របីខ្វកមានជ័យ ត្រូវបានបង្កើតឡើងដោយមហា សន្និបាតលើកដំបូងនៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៦ និងបានចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍លើកទី១នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៧ ដែលបានរៀបចំផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ដោយបានអនុវត្តចាប់ពីឆ្នាំ២០០៨ ដល់ ឆ្នាំ២០១០ ត្រូវបានក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទប្រកាសទទួលស្គាល់នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៨។ រហូតដល់បច្ចុប្បន្ន សហគមន៍នេសាទត្រើយអូរក្របីខ្វកមានជ័យមិនទាន់រៀចំការបោះឆ្នោតឡើងវិញទេ ហើយភាពផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ត្រើយអូរក្របីខ្វកមានជ័យនឹងបានធ្វើបច្ចុប្បន្នភាពនៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៧ ដោយមានចូលរួមពីគណៈកម្មការ និងសមាជិកសហគមន៍នេសាទ មេភូមិត្រើយអូរ ក្រុមប្រឹក្សា ជាពិសេសបានគាំទ្រថវិកាពីរដ្ឋបាលជលផល និងការគាំទ្របច្ចេកទេសពីរដ្ឋបាលជលផលថ្នាក់កណ្តាល និងសម្របសម្រួលដោយខណ្ឌរដ្ឋបាលជលផលកំពង់ធំ ។

គណៈកម្មការសហគមន៍នេសាទត្រូវបានបោះឆ្នោតចំនួនតែ ០១ អាណត្តិ រហូតមកដល់ពេលបច្ចុប្បន្ន ព្រមទាំងបានអនុវត្តភារៈកិច្ចរបស់ខ្លួនដែលស្របតាមលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង ផែនទីព្រំប្រទល់កន្លែងនេសាទសហគមន៍ និងកិច្ចព្រមព្រៀងកន្លែងនេសាទ ។ ទន្ទឹមនឹងនេះ គណៈកម្មការ សហគមន៍នេសាទ ត្រូវបានកសាងសមត្ថភាពតាមរយៈការចូលរួមបណ្តុះបណ្តាល សិក្ខាសាលា ប្រជុំបណ្តាញការងារ ទស្សនៈកិច្ចសិក្សា និងរៀនសូត្រតាមឯកសារផ្សេងៗ ។

ដូច្នេះផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍**ត្រើយអូរក្របីខ្វកមានជ័យ**បានធ្វើការកែសម្រួលសកម្មភាពសំខាន់ៗ និងថវិកាដែលគ្រោង ដើម្បីអាចធានាដល់ការគ្រប់គ្រងធនធានជលផលនៅក្នុងកន្លែងអភិរក្សសហគមន៍នេសាទនិងប្រជាពលរដ្ឋមូលដ្ឋានទទួលបានផលប្រយោជន៍ពីធនធានជលផលប្រកបដោយនិរន្តភាព និងសមធម៌។

## ២-អំពីប្រជាសាស្ត្រ និង សេដ្ឋកិច្ចសង្គម

### ក.ប្រជាពលរដ្ឋ

នៅពេលបច្ចុប្បន្ន ក្នុងឃុំព្នៅ មានចំនួន០៣ភូមិ គឺ ភូមិត្រើយអូរ ភូមិព្នៅ និងភូមិកងមាស ដែលមានប្រជាពលរដ្ឋសរុបចំនួន ២៦៨២នាក់ ក្នុងនោះស្រីមានចំនួន ១៤០៧ នាក់ ហើយមានចំនួន ៦៧១ គ្រួសារ ដោយឡែកគ្រួសារ ដែលមានស្ត្រីជាមេគ្រួសារចំនួន ៧៨ គ្រួសារ។ សហគមន៍នេសាទត្រើយអូរក្របីខ្វកមានជ័យគ្រប ដណ្តប់តែចំនួន ០១ ភូមិគឺភូមិត្រើយអូរ ដែលមានប្រជាពលរដ្ឋសរុបចំនួន ២៣២ គ្រួសារ ហើយមនុស្សសរុបចំនួន ៩៨៥ នាក់ ក្នុងនោះស្ត្រីមានចំនួន៥១១នាក់ដោយឡែកគ្រួសារដែលមានស្ត្រីជាមេគ្រួសារមានចំនួន ២៨ គ្រួសារ ។

ផ្អែកតាមការធ្វើអត្តសញ្ញាណកម្មគ្រួសារក្រីក្រ នៅក្នុងត្រើយអូរក្របីខ្វកមានជ័យ បានបង្ហាញថា គ្រួសារដែលស្ថិតក្នុងស្ថានភាពក្រីក្រ ១ មានចំនួន ៣២ គ្រួសារ និងស្ថានភាពក្រីក្រ ២ មានចំនួន ១៦ គ្រួសារ ដែលសរុប

ចំនួន ៤៨ គ្រួសារ ហើយសហគមន៍នេសាទ ត្រើយអូរក្របីខ្វកមានជ័យ មានប្រជាពលរដ្ឋជាជនជាតិខ្មែរ ហើយគោរពព្រះពុទ្ធសាសនាដែលមានស្ថានភាពដូចជា៖

- ចំនួនស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមាន ៣៤ នាក់
- ចំនួនបុរសពោះម៉ាយក្នុងសហគមន៍នេសាទមាន ២ នាក់
- ចំនួនជនពិការក្នុងសហគមន៍នេសាទមាន ៤ នាក់ ក្នុងនោះស្ត្រីមានចំនួន ១នាក់
- ចំនួនចាស់ជរាក្នុងសហគមន៍នេសាទមាន ១១ នាក់ក្នុងនោះស្ត្រីមានចំនួន ៩នាក់
- ចំនួនអ្នកមានជម្ងឺរាំរ៉ៃក្នុងសហគមន៍នេសាទមាន ០១ នាក់
- សាលារៀនបឋមនិងអនុវិទ្យាល័យចំនួន៩ខ្នង មានចំនួនសិស្ស១២៧នាក់ក្នុងនោះកុមារីមានចំនួន៨៨ នាក់
- ចំនួនគ្រួសារដែលកើតមេរោគអេដ៍មានចំនួន ០១ នាក់
- តាមរបាយការណ៍របស់ក្រុមប្រឹក្សាឃុំ សង្កាត់ បានបង្ហាញថា **ត្រើយអូរក្របីខ្វកមានជ័យ**មានអ្នកមិនចេះអក្សរមានចំនួន ៥០នាក់ ក្នុងនោះស្ត្រីមានចំនួន ២០ នាក់ ។

## ខ.សេដ្ឋកិច្ចសង្គម

តាមរបាយការណ៍ និងឯកសារព័ត៌មានសង្កាត់ឆ្នាំ ២០១៧ បានបញ្ជាក់ថានៅក្នុងសហគមន៍**ត្រើយអូរក្របីខ្វកមានជ័យ** មានប្រពលរដ្ឋដែលពឹងផ្អែកលើការធ្វើស្រែភាគច្រើន និងការនេសាទ ក្រៅពីនេះស្ត្រីគ្រាន់តែជាអ្នកប្រកបមុខរបរបន្ទាប់បន្សំដូចជា ការចិញ្ចឹមត្រី កែច្នៃប្រហុក និងលក់ដូរជាដើម។ ការគាំទ្រមុខរបរចិញ្ចឹមជីវិតដល់សមាជិកសហគមន៍នេសាទ ជាសកម្មភាពចំបងដែលជួយពង្រីកមុខរបរដល់ប្រជានេសាទនៅក្នុងសហគមន៍ ជាពិសេស បានជួយកាត់បន្ថយសម្ពាធនៃការធ្វើអាជីវកម្មលើធនធានជលផលហួសកំរិត ។ កន្លងមករដ្ឋបាលជលផល និងអង្គការដៃគូអភិវឌ្ឍន៍បានជួយបណ្តុះបណ្តាលអំពីបច្ចេកទេសការចិញ្ចឹមសត្វ និងការចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ ព្រមទាំងមុខរបរចិញ្ចឹមជីវិតផ្សេងៗ ទៀតដល់សមាជិកសហគមន៍នេសាទ ដើម្បីរួមចំណែកជួយលើកស្ទួយសេដ្ឋកិច្ចគ្រួសារឲ្យមានការរីកចំរើន ។

ពេលបច្ចុប្បន្ន នៅក្នុងសហគមន៍នេសាទ**ត្រើយអូរក្របីខ្វកមានជ័យ** ប្រជាពលរដ្ឋមានស្ថានភាពនៃការចិញ្ចឹមជីវិត និងមុខរបរសំខាន់ៗរួមមាន៖

- អ្នកធ្វើស្រែវស្សាមានចំនួន ២៣២ គ្រួសារ
- អ្នកធ្វើស្រែប្រាំងមានចំនួន ១៥ គ្រួសារ
- អ្នកចិញ្ចឹមសត្វប្រហែលមានចំនួន ២០០ គ្រួសារ
- អ្នកចិញ្ចឹមត្រីប្រាតាមបែមានចំនួន ០៣ គ្រួសារដែលបែទំហំជាមធ្យម (៨មx៤មx២ម)
- អ្នកចិញ្ចឹមក្រពើតាមបែមានចំនួន ០១ គ្រួសារ (១០មx៥មx២ម)
- អ្នកកែច្នៃប្រហុកប្រហែលមានចំនួន ១២០ គ្រួសារ
- កម្មករមានប្រហែលចំនួន ១០០ នាក់
- ជាងផ្សារដែកមានចំនួន ០១ គ្រួសារ
- ជាងសាកអាគុយមានចំនួន ០១ គ្រួសារ
- ជាងធ្វើផ្ទះមានចំនួន ០៤ គ្រួសារ
- គ្រូបង្រៀន និងនេសាទ ១១ នាក់
- មន្ត្រីរាជការមានចំនួន ០៦ នាក់
- អ្នកលក់ដូរ ១០ គ្រួសារ និងជាងធ្វើម៉ាស៊ីនកាណូត ០១ គ្រួសារ។

## ៣. កន្លែងនេសាទ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទ

### ក.ទីតាំង

ដូចនេះ សហគមន៍នេសាទ មានព្រំប្រទល់ជាប់នឹង៖

- ខាងជើងទល់នឹង សហគមន៍នេសាទតាមុនលាភ
- ខាងត្បូងទល់នឹង ជាប់ឡូត៍លេខ០៧
- ខាងកើតទល់នឹង ព្រៃកប៊ឹងព្រួល និង
- ខាងលិចទល់នឹង សហគមន៍នេសាទព្មៅអភិវឌ្ឍន៍បឹងកណ្តាល។

### ខ.ដែននេសាទ

កន្លែងនេសាទសហគមន៍នេសាទត្រើយអូរក្របីខ្វកមានជ័យ មានវិសាលភាពគ្រប់ដណ្តប់លើបឹង ស្ទឹង ត្រពាំង និងអូរ ព្រមជាមួយកន្លែងអភិរក្សពូជត្រីដូចជា៖

**ខ.១.បឹង**

| ល.រ | ឈ្មោះបឹង | ទំហំជា ហត | រដូវនេសាទ |
|---|---|---|---|
| ១ | បឹងក្រៃស្នោធំ | ៥៤,៥៨ | ខែ ១០ - ខែ ០៦ |
| ២ | បឹងក្របីខ្វក | ៣៣,១៨ | ខែ ១០ - ខែ ០៦ |
| សរុប | | ៨៧,៧៦ | |

**ខ.២.អូរ វាល និងព្រៃលិចទឹក**

| ល.រ | ឈ្មោះអូរ វាល និងព្រៃលិចទឹក | ទំហំជា ហត | រដូវនេសាទ |
|---|---|---|---|
| ១ | អូរវង្វង់ខែ(មួយចំណែក) | ១,១៤ | ខែ ១០ - ខែ ០៦ |
| ២ | វាលក្របីខ្វកខាងលិច | ១០,០០ | ខែ ១០ - ខែ ០៦ |
| ៣ | ព្រៃលិចទឹកស្រោមសន្ទះ | ២៨,៤៥ | ខែ ១០ - ខែ ០៦ |
| ៤ | ព្រៃលិចទឹកក្របីខ្វក | ១៩,៧២ | ខែ ១០ - ខែ ០៦ |
| ៥ | វាលទំនាបតាសែង | ១១,២៤ | ខែ ១០ - ខែ ០៦ |
| ៦ | វាលក្រៃស្នោធំត្បូង | ៤,១១ | ខែ ១០ - ខែ ០៦ |
| ៧ | វាលក្រៃស្នោធំត្បូង | ៧,០៥ | ខែ ១០ - ខែ ០៦ |
| **សរុប** | | **៧០,៥៥** | |

### គ.តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស

| ល.រ | ឈ្មោះអូរ | ទំហំជា ហត | លទ្ធភាពធ្វើការអភិរក្ស |
|---|---|---|---|
| ១ | បឹងក្របីខ្វក | ១,០០ | ធ្វើការអភិរក្ស |
| ២ | ព្រៃក្របីខ្វក | ១,៥០ | ធ្វើការអភិរក្ស |

កន្លែងនេសាទសហគមន៍ **ត្រើយអូរក្របីខ្វកមានជ័យ** បានផ្តល់នូវលក្ខណៈងាយស្រួលដល់ការរស់នៅ និងការធ្វើនេសាទនៅក្នុងសហគមន៍ក៏ដូចអ្នកមកពីខាងក្រៅសហគមន៍ជាពិសេសកន្លែងនេសាទសហគមន៍មានអំណោយផលល្អដល់ការរស់នៅរបស់ពពួកវារីសត្វ រុក្ខជាតិ ជាពិសេស ជាចំណី និងជម្រកពងកូនរបស់មច្ឆា សត្វស្លាប និងសត្វល្មូនគ្រប់ប្រភេទ។ ម្យ៉ាងទៀត កន្លែងនេសាទសហគមន៍ ត្រើយអូរក្របីខ្វកមានជ័យ ជាក់ស្តែងបាន

ភ្ជាប់ជាមួយបឹង វាល និងអូរ និងព្រៃលិចទឹកដែលទទួលរបបទឹកពីបឹងទន្លេសាប ហើយផ្តល់ផលប្រយោជន៍យ៉ាងច្រើនដល់កសិកម្ម ។

ដែននេសាទសំខាន់ៗនៅក្នុងសហគមន៍ត្រើយអូរក្របីខ្វកមានជ័យមានបឹងចំនួន ០២ បឹងដែលមានទំហំប្រមាណ ៨៧,៧៦ហិកតា អូរ វាល និងព្រៃលិចទឹកមានចំនួន ០៧ កន្លែង ដែលមានទំហំប្រមាណ ៧០,៥៥ ហិកតា តំបន់វាលស្មៅមានទំហំប្រហែល ៨២,១៩ ហិកតា និងកន្លែងអភិរក្សមានចំនួន ០២ កន្លែងដែលមានទំហំប្រមាណ ២,៥០ ហិកតា ។ ដូច្នេះ កន្លែងនេសាទសហគមន៍**ត្រើយអូរក្របីខ្វកមានជ័យ**មានទំហំសរុប ២៤៣,០០ ហិកតា ត្រូវបានកំណត់និយាមកាដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង។

**ឃ.ធនធានជលផល**

**ឃ.១.ប្រភេទត្រី**

មានប្រភេទត្រីដូចជា៖ ត្រីរៀល ត្រីឆ្លាំង ត្រីកេះ ត្រីកញ្ចុះ ត្រីអាចម៍កុក ត្រីក្អែក ត្រីក្តចិន ត្រីឆ្ពិន ត្រីកន្ធ្រប់ ត្រីប្រម៉ា ត្រីក្រសក់ ត្រីក្រាយ ត្រីក្រម៉ម ត្រីខ្ទីង ត្រីគល់រាំង ត្រីខ្លា ត្រីរ៉ស់ ត្រីឆ្តោ ត្រីអណ្តែង ត្រីឆ្តួញ ត្រីកន្ធង ត្រីឆ្កោក ត្រីកញ្ចុះភ្លោង ត្រីក្រពត ត្រីចង្វា ត្រីដំរី ត្រីកំភ្លាញ ត្រីផ្ទក់ ត្រីអណ្តាតឆ្កែ ត្រីឆ្ទៀត ត្រីក្លាំងហាយ ត្រីក្រាញ់ ត្រីព្រួល ត្រីស្លាបមាន់ ត្រីសង្កត់ប្រាក់ ត្រីក្រុះ ត្រីព្រួល ត្រីស្លាត ត្រីពូលូង ត្រីស្រកាក្តាម ត្រីកំភ្លៀវ ត្រីខ្នាន់ ត្រីដៀបត្រីចង្វាមូល ត្រីក្អែកត្រីលិញ

**ឃ.២.ប្រភេទវារីសត្វ**

មានប្រភេទវារីសត្វដូចជា៖ ក្តាម ខ្យង ខ្ចៅ គ្រំ លៀស អណ្តើក កន្ធាយ ពស់ កង្កែប ហ៊ីង គីង្គក់ ពស់ខ្សែគោ អន្ទង់ ក្តាមទូក កន្ធេះឡង់ អន្សង់ ភេ សត្វស្វាក្រះ សំពោច ។ល។

**ឃ.៣.ប្រភេទបក្សី**

មានប្រភេទបក្សីដូចជា៖ ក្អែកទឹក សត្វគ្រៀល សត្វទុង សត្វប្រវឹក សត្វក្រសា សត្វកុកស សត្វមាន់ទឹក សត្វទាព្រៃ សត្វទាទឹក សត្វអូត សត្វសេក សត្វលលក សត្វចាប សត្វត្រយង ។ល។

**ឃ.៤.ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ**

មានប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិដូចជា៖ ដើមរាំងទឹក ដើមតាអូរ ដើមអញ្ចាញ ដើមថ្នាន់ ដើមកន្សែង ដើមបន្លាយួន ដើមស្នាចទឹក ដើមកណ្តាប់ចង្កេរ ដើមរំដេញ ដើមបន្លាស្អិត ដើមច្រកែង ។ល។

**៤. ការធ្វើនេសាទ**

ជាពិសេស នៅក្នុងកំឡុងឆ្នាំ ២០១៧ ដែលមានបញ្ហាគ្រោះរាំងស្ងួតបានធ្វើឱ្យបឹង ស្ទឹង ត្រពាំង និងអូរបានរីងរាក់ ហើយប្រភេទត្រីមេពូជបាននេសាទដោយជនល្មើស ។

**៤.ក.អ្នកនេសាទ**

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន ២៤០ នាក់ ក្នុងនោះស្ត្រីមានចំនួន ១២០ នាក់ ។
- អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទនៅក្នុងសហគមន៍មានចំនួន១៨៥នាក់ក្នុងនោះស្ត្រីមាន៣៨ នាក់។

តាមការប៉ាន់ស្មានអ្នកនេសាទដែលមកពីខាងក្រៅ ហើយមិនមែនជាសមាជិកសហគមន៍មានប្រហែល៣០នាក់ក្នុង១ឆ្នាំ ។

**៤.ខ.ឧបករណ៍នេសាទ**

ឧបករណ៍នេសាទ និងទូកកាណូតរបស់សមាជិកសហគមន៍នេសាទ ដែលប្រើប្រាស់ក្នុងសហគមន៍ដូចជា៖

| ល.រ | ឧបករណ៍នេសាទ | ឯកតា | ប្រវែង/ទំហំ | រដូវនេសាទ |
|---|---|---|---|---|
| ១ | មងរាយ | ម៉ែត្រ | ៣០ម x១,៥ម x២,៥សម | ពីខែ ០៨ ដល់ ខែ ១១ |

| | | | | |
|---|---|---|---|---|
| ២ | សន្ទូចរនង | ផ្លែ | ៥០០ ផ្លែ | ពេញ១ឆ្នាំ |
| ៣ | លប | លប | ២១ | ខែ ០៣ ដល់ ខែ ០៦ |
| ៤ | អួនព្រយុង | វង់ | ៥០០ម x៤ម x៣សម | ខែ ០៣ ដល់ ខែ ០៦ |
| ៥ | សំណាញ់ | វង់ | ៣០ម x១,០ម x០,៥ម | ពេញ១ឆ្នាំ |
| ៦ | បង្កៃ | ផ្លែ | ១៥០ ផ្លែ | ខែ ០៧ ដល់ ខែ ១០ |
| ៧ | បបក់ | ដើម | ផ្លែលេខ ១២ ដល់១៣ | ខែ ០៧ ដល់ ខែ ១០ |
| ៨ | ដាក់លាន់ | លាន់ | ១០ | ខែ ០១ ដល់ ខែ ០២ |
| ៩ | ប៉ោង | ប៉ោង | ៥០ប៉ោង | ខែ ០១ ដល់ ខែ ០៥ |

| ប្រភេទទូក កាណូត | ចំនួន(គ្រឿង) | ចំណុះ(គក្រ) | កំលាំងសេះ |
|---|---|---|---|
| កាណូតម៉ាស៊ីន | ៤៥ | ២០០-២៥០០ | ៦ និង ១៨ |
| ទូកអុំ | ១៥ | ១០០ | |

**ឧបករណ៍នេសាទ និងទូក កាណូតរបស់អ្នកមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍នេសាទ**

| ល.រ | ឧបករណ៍នេសាទ | ឯកតា | ប្រវែង/ទំហំ | រដូវនេសាទ |
|---|---|---|---|---|
| ១ | មងរាយ | ម៉ែត្រ | ៥០ម x១,៥ម x២,៥សម | ពីខែ ០៨ ដល់ ខែ ១១ |
| ២ | សន្ទូចរនង | ផ្លែ | ១០០ ផ្លែ | ពេញ១ឆ្នាំ |
| ៣ | លប | លប | ២១ | ខែ ០៣ ដល់ ខែ ០៦ |
| ៤ | អួនព្រយុង | វង់ | ១៥០ម x៤ម x៣សម | ខែ ០៣ ដល់ ខែ ០៦ |
| ៥ | សំណាញ់ | វង់ | ៣០ម x១,០ម x០,៥ម | ពេញ១ឆ្នាំ |
| ៦ | បង្កៃ | ផ្លែ | ១៥០ ផ្លែ | ខែ ០៧ ដល់ ខែ ១០ |
| ៧ | បបក់ | ដើម | ផ្លែលេខ ១២ ដល់១៣ | ខែ ០៧ ដល់ ខែ ១០ |
| ៨ | ដាក់លាន់ | លាន់ | ១០ | ខែ ០១ ដល់ ខែ ០២ |

| ប្រភេទទូកកាណូត | ចំនួន(គ្រឿង) | ចំណុះ(គក្រ) | កំលាំងសេះ |
|---|---|---|---|
| កាណូតម៉ាស៊ីន | ២០ | ២០០-២៥០០ | ៦ និង ១៨ |

**គ.ការប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ**

ផ្អែកតាមការសិក្សា និងធ្វើការប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំរបស់សមាជិក សហគមន៍នេសាទមានក្នុងតារាងខាក្រោម៖

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ(គិតជា គក្រ) | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រីគ្រប់ប្រភេទ | ២៥០ | ២០០ | ៤៥០ |
| ក្តាម ខ្យង ខ្ចៅ និងលៀស | ១៥ | ៧៥ | ៩០ |
| អន្ទង់ | ១៧ | ៨៩ | ១០៦ |
| **សរុប** | **២៨២** | **៣៦៤** | **៦៤៦** |

## ៥.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### ក.ទស្សនៈវិស័យ

សហគមន៍នេសាទ មានទស្សនៈវិស័យរួមចំណែកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលប្រកបដោយសមធម៌ និងនិរន្តរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

### ខ.គោលបំណង

- ចូលរួមគ្រប់គ្រងដែននេសាទទឹកសាបជាកន្លែងនេសាទគ្រួសារ ដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណី ឬសហគមន៍ធ្វើនេសាទ ទំនាបលិចទឹកក្នុងរដូវទឹកដំឡើង ព្រៃលិចទឹក និងកន្លែងអន្លង់អភិរក្ស។
- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព និងធានាការបែងចែកផលប្រយោជន៍ធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌។
- ដើម្បីធ្វើឲ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍នេសាទតាមរយៈការអភិវឌ្ឍន៍ចំរុះដោយមានការចូលរួម។
- ដើម្បីឲ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ នឹងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់ផ្ទាល់លើធនធានធម្មជាតិ។

### គ.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

#### គ.១ ផែនការប្រើប្រាស់ឧបករណ៍នេសាទ:

#### គោលបំណង

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍គឺ រៀបចំឡើងដោយបានគិតគូរអំពីប្រភេទដែននេសាទ ប្រភេទទំហំ ប្រវែងចំនួនឧបករណ៍នេសាទចំនួនអ្នកនេសាទ និង រដូវនេសាទ និងការប៉ាន់ប្រមាណផលស្តុកដែលមាននៅក្នុងដែននេសាទដោយធ្វើយ៉ាងណាមិនឱ្យការធ្វើនេសាទលើសពីតម្រូវការធនធានជលផលដែលមានក្នុងកន្លែងសហគមន៍នេសាទ។

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទត្រូវបានរៀបចំឡើងដូចខាងក្រោម:

| ល.រ | ឧបករណ៍នេសាទ | ឯកតា | ប្រវែង/ទំហំ | រដូវនេសាទ |
|---|---|---|---|---|
| ១ | មងរាយ | ម៉ែត្រ | ៣០ម x១,៥ម x២,៥សម | ពីខែ ០៨ ដល់ ខែ ១១ |
| ២ | សន្ទូចរនង | ផ្លែ | ៥០០ ផ្លែ | ពេញ១ឆ្នាំ |
| ៣ | លប | លប | ២១ | ខែ ០៣ ដល់ ខែ ០៦ |
| ៤ | អួនព្រួយុង | វង់ | ៥០០ម x៤ម x៣សម | ខែ ០៣ ដល់ ខែ ០៦ |
| ៥ | សំណាញ់ | វង់ | ៣០ម x១,០ម x០,៥ម | ពេញ១ឆ្នាំ |
| ៦ | បង្កៃ | ផ្លែ | ១៥០ ផ្លែ | ខែ ០៧ ដល់ ខែ ១០ |
| ៧ | បបក់ | ដើម | ផ្លែលេខ ១២ ដល់១៣ | ខែ ០៧ ដល់ ខែ ១០ |
| ៨ | ដាក់លាន់ | លាន់ | ១០ | ខែ ០១ ដល់ ខែ ០២ |
| ៩ | ប៉ោង | ប៉ោង | ៥០ប៉ោង | ខែ ០១ ដល់ ខែ ០៥ |

| លរ | ឈ្មោះបឹង | រដូវនេសាទ | ប្រភេទ ឧបករណ៍ | ប្រវែង /គ្រួសារ | ចំនួន គ្រួសារ |
|---|---|---|---|---|---|
| ១ | បឹងព្រៃស្មោធំ | ខែ០៦-ខែ០៩ | មង សន្ទូច លប បបក់ អួន | ៥០០ម, ៥០០ផ្លែ, ២១ | ៣០ |

| | | | | | |
|---|---|---|---|---|---|
| | | | ព្រយុង សំណាញ់ លាន់ | លប, ១ដើម, ៥០០ម ១វង់ និង ១០ លាន់ | |
| ២ | បឹងក្របីខ្វក | ខែ០៦-ខែ០៩ | មង សន្ទូច លប បបក់ អួន ព្រយុង សំណាញ់ លាន់ | ៥០០ម, ៥០០ផ្លែ, ២១ លប, ១ដើម, ៥០០ម ១វង់ និង ១០ លាន់ | ៨៥ |

**គ.២.ផែនការកែលំអដែននេសាទ**

ផែនការកែលំអដែននេសាទ គឺជាការងារមួយដែលត្រូវទាមទារមានការគាំទ្របច្ចេកទេស និងថវិកា និងប្រើប្រាស់ពេលវេលាធ្វើការសិក្សាមួយច្បាស់លាស់ពីព្រោះថា ការកែលំអដែននេសាទសហគមន៍នេះ ពាក់ព័ន្ធជាមួយត្រីមេពូជ និងវារីសត្វគ្រប់ប្រភេទនៅក្នុងដែននេសាទនោះ។ ដូច្នេះ ក្នុងកិច្ចប្រជុំរវាងគណៈកម្មការ សមាជិកសហគមន៍នេសាទ អាជ្ញាធរមូលដ្ឋាន និងក្រុមសម្របសម្រួលរដ្ឋបាលជលផលបានពិនិត្យឃើញថា ដែននេសាទនៅក្នុងសហគមន៍នេសាទត្រើយអូរក្របីខ្វកមានជ័យ មានសភាពប្រែប្រួលខ្លះដែលបណ្តាលមកពីកត្តាមនុស្ស និងធម្មជាតិ ។

ផែនការកែលំអដែននេសាទ ក្នុងគោលបំណង៖

- បង្កើនផលត្រី និងវារីសត្វគ្រប់ប្រភេទ និងជួយថែរក្សាលំនឹងបរិស្ថានធម្មជាតិ
- ធ្វើឲ្យសំបូរព្រៃលិចទឹកក្នុងដែននេសាទសហគមន៍ និង
- ទាក់ទាញភ្ញៀវទេសចរណ៍ ។

ផែនការកែលំអដែននេសាទ នឹងត្រូវរៀបចំដូចមានក្នុងតារាងខាងក្រោម៖

| ឈ្មោះដែន នេសាទ | ទំហំ | ទំហំដែលត្រូវ កែលំអ | សកម្មភាព | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ផែនការស្តារទំនប់ព្រែកក្របីខ្វក | ១ហិកតា | ប=៤០ម ខ្នងលើ:៣ម បាត:៦ម កំពស់:២ម | ធ្វើការសិក្សា | ១/០១/២០១៩ | ១/០៤/២០១៩ |
| | | | ការស្តារព្រែក | ១/០១/២០២០ | ១/១២/២០២០ |

**គ.៣ ផែនការរៀបចំកន្លែងអភិរក្ស**

សហគមន៍នេសាទ**ត្រើយអូរក្របីខ្វកមានជ័យ** បានសម្រេចក្នុងការបង្កើតកន្លែងអភិរក្សចំនួន ០២ កន្លែងគឺ បឹងក្រែស្នោធំ និង បឹងក្របីខ្វក ដែលជាកន្លែងមានសក្តានុពលសម្រាប់អភិរក្សត្រីមេពូជ ។ ដូចនេះ កន្លែងអភិរក្សបានធ្វើការគ្រប់គ្រងបន្ទាប់ពីសហគមន៍នេសាទនេះ ត្រូវបានប្រកាសទទួលស្គាល់ដោយក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ហើយកន្លែងអភិរក្សត្រីមេពូជទាំងពីរ នេះបង្កើតឡើងក្នុងគោលបំណង៖

- បង្កើនពូជត្រី និងសត្វគ្រប់ប្រភេទ
- ថែរក្សាការពារព្រៃលិចទឹក ដែលជាជម្រកនិងប្រភពចំណីរបស់ត្រីនិងសត្វ
- ផ្តល់ចំណេះដឹងដល់ប្រជាពលរដ្ឋ ឱ្យចេះស្រឡាញ់ថែរក្សា ការពារធនធានធម្មជាតិ និង
- ពិសេស ធនធានជលផល បរិស្ថាន និងចូលរួមលុបបំបាត់ការនេសាទខុសច្បាប់។

តាមការចុះអង្កេត និងពិនិត្យរបស់ក្រុមការងារ និងពិភាក្សាលើលក្ខណៈវិនិច្ឆ័យជាមួយគណៈកម្មការ និងសមាជិកសហគមន៍នេសាទ**ត្រើយអូរក្របីខ្វកមានជ័យ**បានបញ្ជាក់ថា កន្លែងអភិរក្សបឹងក្រែស្នោធំ និងបឹងក្របីខ្វក គឺជាកន្លែងសំខាន់បំផុតសម្រាប់ធ្វើការអភិរក្សដែលសមាជិកសហគមន៍នេះ មានសុឆន្ទៈចង់ចូលរួមក្នុងការគ្រប់គ្រង

ធនធានជលផល ដើម្បីធានានូវប្រសិទ្ធភាពនៃការគ្រប់គ្រងធនធានជលផល និងជាប្រយោជន៍សម្រាប់តម្រូវការផល ត្រីរបស់ ប្រជាពលរដ្ឋក្នុងសហគមន៍ ។

កន្លែងអភិរក្សត្រីមេពូជ ជាកត្តាចាំបាច់ដែលត្រូវរៀបចំកំណត់ព្រំប្រទល់បោះបង្គោលស៊ីម៉ង់ត៍ ធ្វើប៉ាណូផ្សព្វផ្សាយ ក្តារខៀនព័ត៌មាន បិទផ្សាយបទបញ្ញត្តិផ្សេងសម្រាប់កន្លែងអភិរក្ស សាងសង់រោងយាមសម្រាប់ក្រុមល្បាតបំពេញការងារ មធ្យោបាយ និងសម្ភារៈផ្សេងទៀត។

ផែនការកំណត់ និងរៀបចំកន្លែងអភិរក្សនឹងត្រូវរៀបចំដូចមានក្នុងតារាងខាងក្រោម៖

| ឈ្មោះ /ទីតាំង | ទំហំ (ហាត) | ប្រភេទ នៃការអភិរក្ស | សកម្មភាព | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| បឹងក្របីខ្វក (អន្លង់ក្របីខ្វក) | ១ហាត | • ប្រភេទត្រីសំខាន់<br>• ប្រភេទសត្វស្លាប<br>• ប្រភេទពពួកល្មូន<br>• ព្រៃលិចទឹក | • សិក្សាលើទីតាំង<br>• ដាក់គល់ឈើចំនួន ២០០ គល់<br>• បង្គោលស៊ីម៉ង់ចំនួន ៤ដើម<br>• ធ្វើប៉ាណូផ្សព្វផ្សាយ ៤ផ្ទាំង<br>• ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ<br>• ចុះល្បាតជាប្រចាំ | ២០១៧ | ២០២០ |

**គ.៤ ផែនការគ្រប់គ្រងព្រៃលិចទឹក**

នាទីព្រៃលិចទឹកបានគ្របដណ្តប់លើដែននេសាទសហគមន៍ត្រើយអូរក្របីខ្វកមានជ័យ ដែលបានផ្តល់នូវសក្តានុពល និងសារៈប្រយោជន៍ជាច្រើនដល់ប្រភេទត្រី ពពួកសត្វល្មូន ប្រភេទសត្វ និងវារីសត្វផ្សេងទៀតសម្រាប់ជាជម្រករស់នៅបង្កកំណើតជាកូន និងជាចំណីផងដែរ។ដូចនេះ ផែនការគ្រប់គ្រងព្រៃលិចទឹកក្នុងគោលបំណង៖

- ថែរក្សា ការពារព្រៃលិចទឹកឱ្យនៅគង់វង្សយូរអង្វែងដល់ក្មេងជំនាន់ក្រោយ។
- ទុកជាជម្រកត្រី និងវារីសត្វគ្រប់ប្រភេទ និងជួយថែរក្សាលំនឹងបរិស្ថានធម្មជាតិ និងជារបាំងខ្យល់។
- បង្កើនទិន្នផលត្រី និងពពួកសត្វមានជីវិតគ្រប់ប្រភេទឲ្យសំបូរឡើង ដើម្បីលើកកម្ពស់ជីវភាពរស់នៅ។

គណៈកម្មការ និងសមាជិកសហគមន៍នេសាទ**ត្រើយអូរក្របីខ្វកមានជ័យ**បានកំណត់ និងបែងចែកនាទីព្រៃលិចទឹក កន្លែងអភិរក្ស និងកន្លែងប្រើប្រាស់ព្រៃលិចទឹកដោយផ្អែកតាមផែនទីសហគមន៍នេសាទ។ កន្លែងប្រើប្រាស់ព្រៃលិចទឹក ត្រូវអប់រំណែនាំដល់ប្រជាពលរដ្ឋឱ្យចេះកាប់រំលោះមែកដែលធ្វើយ៉ាងណាមិនឲ្យងាប់ដើម ដើម្បីយកមកប្រើប្រាស់ជាអុសចំអិនអាហារ។ ការកាប់រំលោះនេះធ្វើជាលក្ខណវិលជុំជារៀងរាល់បីឆ្នាំម្តង ដើម្បីទុកឱ្យព្រៃមានលទ្ធភាពអាចដុះលូតលាស់ឡើងវិញបាន។

ដោយសារការយល់ដឹងពីសារៈសំខាន់នៃនាទីព្រៃលិចទឹក ប្រជាពលរដ្ឋមានការចូលរួមចំណែកយ៉ាងសកម្មក្នុងការគ្រប់គ្រងធនធានជលផលឱ្យប្រសើរឡើង ។

ខាងក្រោមនេះជាផែនការគ្រប់គ្រងនាទីព្រៃលិចទឹកក្នុងសហគមន៍ត្រើយអូរក្របីខ្វកមានជ័យមានដូចជា៖

| ឈ្មោះ/ទីតាំង | ទំហំជាហាត | ប្រភេទកូនឈើ | សកម្មភាព | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| វាលព្រៃគ្រៃ ស្មោធំត្បូង (ដាំព្រៃលិចទឹក) | ២ | រាំង ផ្ទោល គ្រួ និង ប្រកែង ។ល។ | • ផ្សព្វផ្សាយពីព្រៃលិចទឹក<br>• រៀបចំកូនឈើ<br>• ពិធីដាំកូនឈើ<br>• ស្លាកសញ្ញា និងការពារ | ២០១៧ | ២០២០ |
| ព្រៃលិចទឹក | ៦៨,២០ | | • កំណត់ព្រំប្រទល់ហាមចូល | ២០១៧ | ២០២០ |

| | | | | | |
|---|---|---|---|---|---|
| ក្របីខ្វក (ព្រៃអភិរក្ស) | | | • ស្លាកសញ្ញាការពារ<br>• ថែរក្សា និងការពារ | | |

## គ.៥ ផែនការអភិវឌ្ឍន៍វារីវប្បកម្ម

ក្រៅពីនេសាទត្រី ការចិញ្ចឹមត្រីជាមុខរបរចំបងរបស់ប្រជានេសាទនៅក្នុងសហគមន៍ត្រើយអូរក្របីខ្វកមានជ័យ ជាទូទៅ ប្រជាពលរដ្ឋក្នុងសហគមន៍នេសាទនេះ ច្រើនចិញ្ចឹមត្រីនៅតាមស្រះដែលការចិញ្ចឹមត្រីមានដូចជា៖ ត្រីដំរី ត្រីប្រា ត្រីអណ្តែងនិងឆ្តិន។ល ។ ការចិញ្ចឹមត្រីជាទម្លាប់របស់ប្រជាពលរដ្ឋកម្ពុជាជាយូរឆ្នាំមកហើយ ដោយអ្នកខ្លះចាប់បានពូជត្រីពីធម្មជាតិ អ្នកខ្លះទៀតចិញ្ចឹមដូច លក្ខណៈប្រស់ ឬចិញ្ចឹមបំប៉នឱ្យមានទំហំសមស្របសម្រាប់តម្រូវការទីផ្សារ។

ការចិញ្ចឹមត្រីជាទិសដៅដ៏សំខាន់របស់វិស័យជលផល ក្នុងការបង្កើនត្រីសាច់សម្រាប់ហូបចុក របស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន និងសម្រាប់នាំចេញទៅទីផ្សារអន្តរជាតិ ដើម្បីរួមចំណែកជួយលើកស្ទួយសេដ្ឋកិច្ចគ្រួសារឱ្យមានការរីកចំរើន។ ការអភិវឌ្ឍន៍ វារីវប្បកម្មរបស់សហគមន៍នេសាទត្រើយអូរក្របីខ្វកមានជ័យក្នុងគោលបំណង៖

- បង្កើនត្រីសាច់សម្រាប់ហូបចុករបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន
- បង្កើនប្រាក់ចំណូលដែលជួយស្ទួយសេដ្ឋកិច្ចគ្រួសារ
- កាត់បន្ថយសម្ពាធអាជីវកម្មលើធនធានជលផលហួសកំរិត។

ឆ្លើយតបនឹងទៅនឹងការពង្រីកការអភិវឌ្ឍន៍វារីវប្បកម្ម គណៈកម្មការ និងសមាជិកសហគមន៍នេសាទ**ត្រើយអូរក្របីខ្វកមានជ័យ**បានរៀបចំផែនការអភិវឌ្ឍន៍ការចិញ្ចឹមត្រីដូចខាងក្រោម៖

| ប្រភេទវារីវប្បកម្ម | សកម្មភាព | ទំហំ(គិតជាមធ្យម) | ប្រភេទកូនត្រី | បរិមាណ (ក្បាល) | ខែ/ឆ្នាំ | |
|---|---|---|---|---|---|---|
| | | | | | ចាប់ផ្តើម | ប្រមូលផល |
| ចិញ្ចឹមត្រីដំរីតាមបច្ចេកទេសជាលក្ខណៈគ្រួសារ តាមស្រះ ចំនួន ៥គ្រួសារ | • ជ្រើសរើសសមាជិក<br>• បច្ចេកទេសចិញ្ចឹម<br>• ធ្វើស្រះចិញ្ចឹម<br>• ផ្តល់កូនត្រី<br>• តាមដានត្រួតពិនិត្យ | ១ស្រះ ទំហំ ១០ម x៥ម x២ម | ដំរី | ៣,០០០ /គ្រួសារ | ២០១៧ | ២០២០ |
| ចិញ្ចឹមត្រីប្រាតាមបច្ចេកទេសជាលក្ខណៈគ្រួសារ តាមស្រះ ចំនួន ០៧ គ្រួសារ | • ជ្រើសរើសសមាជិក<br>• បច្ចេកទេសចិញ្ចឹម<br>• ធ្វើប៉ែចិញ្ចឹម<br>• ផ្តល់កូនត្រី<br>• តាមដានត្រួតពិនិត្យ | ១ស្រះទំហំ ១០ម x ៥ម x ២ ម | ត្រីប្រា | ៣,៥០០/ គ្រួសារ | ២០១៨ | ២០២០ |
| ចិញ្ចឹមត្រីអណ្តែងតាមបច្ចេកទេសជាលក្ខណៈគ្រួសារ តាមស្រះ ចំនួន ១០ គ្រួសារ | • ជ្រើសរើសសមាជិក<br>• បច្ចេកទេសចិញ្ចឹម<br>• ធ្វើស្រះចិញ្ចឹម<br>• ផ្តល់កូនត្រី<br>• តាមដានត្រួតពិនិត្យ | ១ស្រះទំហំ ១០មx៥ម x ២ម | ត្រីអណ្តែង | ៣,៥០០/ គ្រួសារ | ២០២០ | ២០២០ |
| ចិញ្ចឹមត្រីឆ្តិនតាមបច្ចេកទេសជាលក្ខ | • ជ្រើសរើសសមាជិក<br>• បច្ចេកទេសចិញ្ចឹម | ១ស្រះទំហំ ១០មx៥ម | ត្រីឆ្តិន | ៣,៥០០/ គ្រួសារ | ២០២០ | ២០២០ |

| | | | | | | |
|---|---|---|---|---|---|---|
| ណៈគ្រួសារ ស្រះ ចំនួន ៦ គ្រួសារ | • ធ្វើស្រះចិញ្ចឹម<br>• ផ្តល់កូនត្រី | x ២ម | | | | |

**គ.៦.ផែនការអភិវឌ្ឍន៍មុខរបរទ្រទ្រង់ជីវភាព**

ការគាំទ្រមុខរបរចិញ្ចឹមជីវិតដល់សមាជិកសហគមន៍នេសាទ ជាសកម្មភាពចំបងដែលជួយពង្រីកមុខរបរដល់ប្រជានេសាទនៅងក្នុងសហគមន៍ ជាពិសេស បានជួយកាត់បន្ថយសម្ពាធនៃការធ្វើអាជីវកម្មលើធនធានជលផលហួសកំរិត។ កន្លងមករដ្ឋបាលជលផល និងអង្គការដៃគូអភិវឌ្ឍន៍បានជួយបណ្តុះបណ្តាលអំពីបច្ចេក ទេសការចិញ្ចឹមសត្វ និងការចិញ្ចឹមត្រីលក្ខណៈគ្រួសារ ព្រមទាំងការចិញ្ចឹមជីវិតផ្សេងៗទៀតដល់សមាជិកសហគមន៍នេសាទដើម្បីរួមចំណែកជួយលើកស្ទួយសេដ្ឋកិច្ចគ្រួសារក្នុងគោលបំណង៖

- ដើម្បីឱ្យប្រជាពលរដ្ឋមានមុខរបរបង្កើនប្រាក់ចំណូល
- ជួយកាត់បន្ថយអត្រាចំណាកស្រុក
- ផ្តល់ចំណេះដឹងជំនាញនិងបច្ចេកទេស (ចិញ្ចឹមសត្វ កសិកម្មសមស្រប)

| ប្រភេទមុខរបរ | សកម្មភាព | ប្រភេទពូជ (ក្បាល) | បរិមាណ | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំប្រមូលផល |
|---|---|---|---|---|---|
| ៧គ្រួសារចិញ្ចឹម មាន់ ទា តាមបច្ចេកទេសជាលក្ខណៈគ្រួសារ | • ជ្រើសរើសកសិករស្ម័គ្រចិត្ត<br>• បណ្តុះបណ្តាលចិញ្ចឹមជ្រូក<br>• ធ្វើទ្រុង<br>• ទិញពូជនិងដាក់ពូជចិញ្ចឹម<br>• តាមដានត្រួតពិនិត្យ | មាន់ ទា ក្នុងស្រុក | ៦ក្បាល x៧ គ្រួសារ = ៤២ក្បាល | ២០១៧ | ២០២០ |
| ៧គ្រួសារចិញ្ចឹមជ្រូក តាមបច្ចេកទេសជាលក្ខណៈ គ្រួសារ។ | • ជ្រើសរើសកសិករស្ម័គ្រចិត្ត<br>• បណ្តុះបណ្តាលចិញ្ចឹមជ្រូក<br>• ធ្វើទ្រុង<br>• ទិញពូជនិងដាក់ពូជចិញ្ចឹម<br>• តាមដានត្រួតពិនិត្យ | ពូជក្នុងស្រុក<br>២ក្បាល/គ្រួសារ | ១៤ក្បាល | ២០១៧ | ២០២០ |

**គ.៧. ផែនការអភិវឌ្ឍន៍កម្មវិធីចំរុះ**

**គោលបំណង**

- ដើម្បីឱ្យប្រជាពលរដ្ឋមានមុខរបរនិងមានដើមទុនសំរាប់បង្កើនប្រាក់ចំណូល
- កាត់បន្ថយអត្រាការប្រាក់ខ្ពស់និងខ្ចីប្រាក់ពីឈ្មួញ
- ដើម្បីឱ្យសហគមន៍មានដើមទុនសម្រាប់អនុវត្តការងារដោយខ្លួនឯង

| ប្រភេទមុខរបរ | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|
| បង្កើតក្រុមសន្សំប្រាក់ ១ក្រុម (១៥ គ្រួសារ) | • ផ្សព្វផ្សាយទស្សនៈក្រុមសន្សំដល់សហគមន៍<br>• ជ្រើសរើសប្រធាន អនុប្រធាន និងហិរញ្ញិក<br>• បង្កើតគោលការណ៍ ផ្តល់ទុន<br>• បណ្តុះបណ្តាលពីការរៀបចំឯកសារ និងថវិកា<br>• ត្រួតពិនិត្យតាមដាន | ២០១៧ | ២០២០ |

## គ.៨ ផែនការពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍នេសាទ

ជាទូទៅ បេក្ខជនដែលឈរឈ្មោះជាគណៈកម្មការសហគមន៍នេសាទគួរត្រូវបានបញ្ជាក់ពីគុណភាព និងចំណេះដឹងដូចជា៖ ចេះអាន សរសេរ អាកប្បកិរិយាសមរម្យ ដោយឯកភាពពីសមាជិកសហគមន៍ ហើយការរៀបចំបោះឆ្នោតជ្រើសរើសជាគណៈកម្មការបានប្រើនីតិវិធីដែលស្របតាមគោលការណ៍ណែនាំសហគមន៍នេសាទ ដែលបានអនុម័តដោយក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ។ ជាក់ស្តែង គណៈកម្មការសហគមន៍នេសាទនេះ ត្រូវបានជ្រើសរើសតាមរយៈការបោះឆ្នោតដោយត្រឹមត្រូវ និងយុត្តិធម៌ដែលមានសំឡេងគាំទ្រច្រើនជាងគេ ហើយជាញឹកញាប់សមាសភាពគណៈកម្មការសហគមន៍នេសាទមានកំរិតលើការយល់ដឹងពីលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ជំនាញសម្របសម្រួល ទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍ និងការរៀបផែនការគ្រប់គ្រងកន្លែងសហគមន៍នេសាទ។ ដូចនេះផែនការបណ្តុះបណ្តាលដល់សមាសភាពគណៈកម្មការសហគមន៍នេសាទនឹងត្រូវបានរៀបចំក្នុងគោលបំណង

- យល់ពីតួនាទីនិងភារកិច្ចរបស់ពួកគាត់ និង
- បង្កើនសាមគ្គីភាពនិងការទំនាក់ទំនងល្អជាមួយសហគមន៍ និងអ្នកពាក់ព័ន្ធ
- គណៈកម្មការនឹងអាចអនុវត្តសកម្មភាពក្នុងការងារ។ ផែនការបណ្តុះបណ្តាលមានដូចជា៖

| ល.រ | សកម្មភាព | ចំនួន | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|
| ១ | បណ្តុះបណ្តាលរបៀបធ្វើកំណត់ហេតុ សរសេរលិខិតរដ្ឋបាលរបាយការណ៍ និងរៀបចំទុកឯកសារ | ១លើក | ២០១៧ | ២០១៧ |
| ២ | បណ្តុះបណ្តាលការគ្រប់គ្រងថវិកា | ១លើក | ២០១៨ | ២០១៨ |
| ៣ | បណ្តុះបណ្តាលការដោះស្រាយទំនាស់ | ១លើក | ២០១៨ | ២០១៨ |
| ៤ | បណ្តុះបណ្តាលជំនាញក្នុងការសម្របសម្រួល | ១លើក | ២០១៩ | ២០១៩ |
| ៥ | បណ្តុះបណ្តាលការរៀបចំផែនការ | ១លើក | ២០២០ | ២០២០ |

## គ.៩. ផែនការផ្សព្វផ្សាយពីច្បាប់ជលផល និងលិខិតបទដ្ឋានពាក់ព័ន្ធ

ពេលបច្ចុប្បន្ន ធនធានជលផលក្នុងសហគមន៍ត្រើយអូរក្របីខ្វកមានជ័យកំពុងទទួលរងនូវការគំរាមកំហែងពីអ្នកខាងក្នុង និងខាងក្រៅសហគមន៍ បានកាប់រានព្រៃលិចទឹក និងការប្រើប្រាស់ឧបករណ៍នេសាទល្មើសច្បាប់។ ដូចនេះ ដើម្បីធានាការប្រើប្រាស់ធនធានជលផលនាពេលអនាគត និងបានយូរអង្វែងនោះ តម្រូវធ្វើការផ្សព្វផ្សាយអំពីច្បាប់ស្តីពី ជលផល និងលិខិតបទដ្ឋានពាក់ព័ន្ធឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋនៅមូលដ្ឋាន ដើម្បីឱ្យមានការយល់ដឹងគ្រប់គ្រាន់ និងចូលរួមចំណែកក្នុងការគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តភាព ។ ការផ្សព្វផ្សាយអំពីច្បាប់ស្តីពី ជលផល និងលិខិតបទដ្ឋានពាក់ព័ន្ធក្នុងគោលបំណង៖

- បង្កើនការយល់ដឹងដល់ប្រជាពលរដ្ឋក្នុងសហគមន៍
- កាត់បន្ថយសកម្មភាពបទល្មើសនេសាទក្នុងសហគមន៍

ផែនការសកម្មភាពមានដូចខាងក្រោម៖

| ឈ្មោះសកម្មភាព | អ្នកទទួលខុសត្រូវ | រយៈពេលអនុវត្ត | | | តម្លៃប៉ាន់ស្មាន (គិតជារៀល ) | ប្រភពទុន |
|---|---|---|---|---|---|---|
| | | ខែ៨ ឆ្នាំ២០១៧-ខែ០៨ ឆ្នាំ២០២០ | | | | |
| ផ្សព្វផ្សាយពីច្បាប់ជលផល និងលិខិតបទដ្ឋានពាក់ព័ន្ធ | ខណ្ឌរដ្ឋបាលជលផល | ៤ | ៤ | ៤ | ១.២០០.០០០ | ដៃគូអភិវឌ្ឍន៍ រដ្ឋបាលជលផល |
| ផ្សព្វផ្សាយលក្ខន្តិកៈ និងបទបញ្ជា | គណៈកម្មការ | ៤ | ៤ | ៤ | ៤៨០.០០០ | ថវិកាឃុំ ដៃគូអភិវឌ្ឍ |

## គ.១០.ផែនការសាងសង់ស្នាក់សហគមន៍នេសាទត្រើយអូរក្របីខ្វកមានជ័យ

ពេលបច្ចុប្បន្ន ត្រើយអូរក្របីខ្វកមានជ័យ ពុំទាន់មានស្នាក់សម្រាប់ធ្វើការឡើយដែលគណៈកម្មការមានការលំបាកក្នុងពេលបំពេញការងារ ក៏ដូចជាការងារទំនាក់ទំនងជាមួយក្រុមការងារផ្សេងៗ ឬភ្ញៀវទេសចរណ៍ជាដើម។ ដូចនេះ គម្រោងជួសជុលស្នាក់ការសហគមន៍មានដូចខាងក្រោម៖

| ប្រភេទសកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | តម្លៃប៉ាន់ ស្មាន (រៀល) | ប្រភពទុន |
|---|---|---|---|---|
| សាងសង់ស្នាក់ការសហគមន៍ | ២០១៧ | ២០២០ | ២៤.០០០.០០០ | រាជរដ្ឋាភិបាល អង្គការដៃគូ សប្បុរសជន |
| តុ កៅអី និងទូឯកសារ | ២០២២ | ២០២២ | ១.០០០.០០០ | |

## គ. ១១.ផែនការថវិកាសម្រាប់អភិវឌ្ឍន៍សហគមន៍

ដោយឡែក គណៈកម្មការសហគមន៍នេសាទត្រើយអូរក្របីខ្វកមានជ័យត្រូវដើរតួនាទីសំខាន់ក្នុងការស្វែងរកប្រាក់ចំណូលពីប្រភពផ្សេងៗដូចជា ភាគទានពីសមាជិកសហគមន៍ អង្គការដៃគូអភិវឌ្ឍន៍ សប្បុរស ជន ក្រុមប្រឹក្សាឃុំ និងការធ្វើទស្សនៈកិច្ចរបស់ភ្ញៀវមកក្នុងសហគមន៍នេសាទ ។

ដូចនេះ ផែនការស្វែងរកថវិការសម្រាប់ទ្រង់សហគមន៍នេះមានក្នុងតារាងខាងក្រោះ

| ប្រភេទចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | តម្លៃប៉ាន់ស្មាន(រៀល) |
|---|---|---|---|---|
| ភាគទានប្រចាំឆ្នាំ សមាជិកសហគមន៍ | ប្រជុំផ្សព្វផ្សាយ និងប័ណ្ណភាគទាន | ខែ៨ ឆ្នាំ២០១៧ | ខែ៨ឆ្នាំ២០២០ | ១.៧៥០.០០០ |
| ពីអ្នកនេសាទខាងក្រៅ ឬអ្នកមិនមែនជាសមាជិក | ចេញបណ្ណភាគទាន | ខែ៨ ឆ្នាំ២០១៧ | ខែ៨ឆ្នាំ២០២០ | ៣.២៥០.០០០ |
| សប្បុរសជននិងអង្គការដៃគូអភិវឌ្ឍន៍ | បង្កើតមុខរបរ | ខែ៨ ឆ្នាំ២០១៧ | ខែ៨ឆ្នាំ២០២០ | ៤.០០០.០០០ |
| ក្រុមប្រឹក្សាឃុំ | ថែរក្សា ធនធានជលផល | ខែ៨ ឆ្នាំ២០១៧ | ខែ៨ឆ្នាំ២០២០ | ៧៥០.០០០ |

## គ.១២.ផែនការពង្រឹងបណ្តាញសហគមន៍នេសាទ និងចូលរួមប្រជុំផ្សេងៗ

សហគមន៍នេសាទមានសិទ្ធិរៀបចំបណ្តាញសហគមន៍នេសាទ ក្នុងគោលបំណងចែករំលែកព័ត៌មាន និងបទពិសោធន៍ និងមេរៀនដែលបានរៀនសូត្រ ក្នុងការគ្រប់គ្រង និងការអភិវឌ្ឍន៍សហគមន៍នេសាទក្នុងព្រះរាជា

ណាចក្រកម្ពុជា សម្រាប់ជាផលប្រយោជន៍រួមរបស់សហគមន៍នេសាទទាំងអស់។ បណ្តាញសហគមន៍នេសាទ គឺជាការចងសម្ព័ន្ធរួមគ្នារវាងសហគមន៍នេសាទដែលសម្របសម្រួល ដោយសមាជិកដែលបានជ្រើសរើសឆ្លងកាត់ការទទួលខុសត្រូវពីក្រុមសហគមន៍នេសាទ បណ្តាញសហគមន៍នេសាទមានកម្រិតថ្នាក់ស្រុកខេត្ត តំបន់ និងថ្នាក់ជាតិ។

បណ្តាញសហគមន៍នេសាទនីមួយៗ នឹងត្រូវបានបង្កើតឡើងតាមរយៈការបោះឆ្នោតជ្រើសរើសចេញពីប្រធានគណៈកម្មការសហគមន៍នេសាទពាក់ព័ន្ធ ដោយសេរីត្រឹមត្រូវ និងយុត្តិធម៌ ។ បណ្តាញសហគមន៍នេសាទនឹងមានតួនាទីជួយសម្របសម្រួល និងបានការគាំទ្រពីរដ្ឋបាលជលផល អាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូ។

បណ្តាញសហគមន៍នេសាទក្នុងគោលបំណង៖

- រំលែកព័ត៌មាន និងបទពិសោធន៍ក្នុងការគ្រប់គ្រង និងការអភិវឌ្ឍន៍សហគមន៍នេសាទ
- បង្កើន ការទំនាក់ទំនងល្អជាមួយសហគមន៍ និងអ្នកពាក់ព័ន្ធ ។

| ល.រ | សកម្មភាព | ចំនួន | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|
| ១ | ប្រជុំបណ្តាញសហគមន៍នេសាទថ្នាក់ស្រុក | ៤ដង/១ឆ្នាំ | ២០១៧ | ២០២០ |
| ២ | ប្រជុំបណ្តាញសហគមន៍នេសាទថ្នាក់ខេត្ត | ១ដង/១ឆ្នាំ | ២០១៧ | ២០២០ |
| ៣ | ប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍នេសាទ | ១ដង/១ខែ | ២០១៧ | ២០២០ |
| ៤ | ចូលរួមប្រជុំប្រចាំខែជាមួយក្រុមប្រឹក្សាឃុំ | ១ដង/១ខែ | ២០១៧ | ២០២០ |

### ឃ.យុទ្ធសាស្ត្រ

នៅក្នុងសហគមន៍នេសាទត្រើយអូរក្របីខ្វកមានជ័យ ត្រូវរៀបចំយុទ្ធសាស្ត្រមួយចំនួន ដើម្បីឱ្យការអនុវត្តផែនការទទួលបានជោគជ័យ ។ យុទ្ធសាស្ត្រទាំងនោះមានដូចខាងក្រោម៖

- បង្កើតគណៈកម្មការសម្រាប់អនុវត្តតាមដានត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តន៍ផែនការរួមមាន៖ សមាជិកគណៈកម្មការសហគមន៍នេសាទ ចាស់ទុំ សមាជិកសហគមន៍នេសាទ ដែលមានបទពិសោធន៍ និងចំណេះដឹងល្អជាពិសេសអំពីបញ្ហានេសាទ
- ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់ចំពោះផែនការណាដែលទាក់ទង នឹងបច្ចេកទេសជលផលដូចជា ការធ្វើផែនការកន្លែងអភិរក្សត្រីមេពូជ ការរៀបចំកន្លែងអភិរក្សព្រៃលិចទឹក កន្លែងអភិរក្សជីវចម្រុះ ការស្តារព្រៃក ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី ការរកថវិកាទ្រទ្រង់ជាដើម
- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការនានា គម្រោងនិងម្ចាស់ជំនួយ ដើម្បីទទួលបានការឧបត្ថម្ភគាំទ្រនិងថវិកាសម្រាប់ដំណើរការអនុវត្តផែនការ
- រៀបចំកម្មវិធីអនុវត្តផែនការតាមដំណាក់កាលនីមួយៗដោយជាក់លាក់
- ស្វែងរកថវិកាពីដៃគូអភិវឌ្ឍន៍ ដើម្បីគាំទ្រដល់ដំណើរការអនុវត្តការគ្រប់គ្រងសហគមន៍នេសាទ
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ដល់សមាជិកសហគមន៍នេសាទនិងអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីជម្រុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រង
- កៀងគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ
- រៀបចំវិធានការចំពោះអ្នកនេសាទមកពីក្រៅសហគមន៍
- ពង្រឹងសមត្ថភាពបច្ចេកទេសនិងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទ ដើម្បីចូលរួមអនុវត្តផែនការ
- បញ្ចូលផែនការគ្រប់គ្រងសហគមន៍នេសាទទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ/សង្កាត់។

## តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ត្រពាំងអូរក្របីខ្មុកមានជ័យរយៈពេល ៣ ឆ្នាំ (ខែ៨ ឆ្នាំ២០១៧-ខែ៨ ឆ្នាំ២០២០)

| ប្រភេទផែនការ/សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ(រៀល) | ប្រភពជំនួយ | ពេលផ្ដើម | ពេលបញ្ចប់ |
|---|---|---|---|---|---|
| **១.ផែនការប្រើប្រាស់ឧបករណ៍នេសាទ** | • កាត់បន្ថយទំនាស់ក្នុងកន្លែងនេសាទសហគមន៍<br>• កាត់បន្ថយការប្រើប្រាស់ឧបករណ៍នេសាទល្មើសច្បាប់<br>• សហគមន៍នឹងអនុវត្តន៍ប្រកាសស្ដីពីការប្រើប្រាស់ឧបករណ៍នេសាទ | | | | |
| ១.១.ប្រជុំផ្សព្វផ្សាយការប្រើប្រាស់ឧបករណ៍នេសាទលក្ខណៈគ្រួសារក្នុង១ឆ្នាំ/២ដង | សមាជិកសហគមន៍នឹងយល់ដឹងពីការការប្រើប្រាស់ឧបករណ៍នេសាទលក្ខណៈគ្រួសារ | ២.០០០,០០០ | រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ សប្បុរសជន | ២០១៧ | ២០២០ |
| ១.២.ផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធ | អ្នកពាក់ព័ន្ធ នឹងចូលរួមផ្សព្វផ្សាយបន្តដល់សហគមន៍នេសាទដទៃទៀត | | | | |
| ១.៣.ត្រួតពិនិត្យ និងតាមដាន | គណៈកម្មការនិងសមាជិកចូលរួមឃ្លាំមើល និងរាយការណ៍ | | | | |
| **២.ផែនការកែលំអដែននេសាទ** | • បង្កើនផលត្រី វារីសត្វគ្រប់ប្រភេទ និងព្រៃលិចទឹក<br>• ជួយថែរក្សាលំនឹងបរិស្ថានធម្មជាតិ | | | | |
| ២.១.ផែនការស្ដារទំនប់ព្រែកក្របីខ្មុក (ប=៨០ម ខ្នងលើ:៣ម បាត:៦ម និងកំពស់:២ម) | • ទំនប់ព្រែកក្របីខ្មុកដែលមានទំហំដូចជា ប=៨០មខ្នងលើ:៣ម បាត:៦ម និងកំពស់:២ម នឹងត្រូវបានស្ដារ<br>• ផ្សព្វផ្សាយដល់អ្នកពាកព័ន្ធទាំងអស់<br>• ធ្វើការសិក្សាលើទំហំដែលត្រូវស្ដារ<br>• ការស្ដារទំនប់ព្រែកក្របីខ្មុក ។ | ១៨.០០០.០០០ | រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ សប្បុរសជន | ២០១៧ | ២០២០ |
| **៣.ការរៀបចំកន្លែងអភិរក្ស បឹងក្របីខ្មុក (អន្លង់ក្របីខ្មុក)** | •ប្រភេទត្រីមេពូជ និងវារីសត្វគ្រប់ប្រភេទ ត្រូវបានធ្វើការអភិរក្ស<br>• ប្រភេទព្រៃលិចទឹកនឹងត្រូវបានការពារ<br>• ប្រជាជននឹងយល់ដឹងពីសារៈសំខាន់កន្លែងអភិរក្ស នឹងចូលរួមថែរក្សា | | | | |
| ៣.១.ការប្រលែងកូនត្រីពូជ និងប្រភេទសត្វល្អូនសំខាន់ៗ ចំនួន ៥០គក/ឆ្នាំ | • ជូនដំណឹងអ្នកពាក់ព័ន្ធ<br>• រៀបចំកូនត្រីពូជ និងសត្វល្អូនសំខាន់ៗ<br>• ពិធីប្រលែងកូនត្រីពូជ និងប្រភេទសត្វល្អូនសំខាន់ៗ | ១.៥០០.០០០ | រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន | ២០១៧ | ២០២០ |
| ៣.២.បោះបង្គោលស៊ីម៉ង់ចំនួន ៤ ដើម នៅកន្លែងអភិរក្ស បឹងក្របីខ្មុក | ចំនួន ៤ដើម នឹងបោះនៅកន្លែងអភិរក្សដោយទទួលស្គាល់ពីស្ថាប័ន ជំនាញជលផល ដែលមានផែនទីសំគាល់កន្លែងអភិរក្ស | ៧.២០០.០០០ | | | |

| | | | | | |
|---|---|---|---|---|---|
| ៣.៣.រៀបចំ និងដាក់គល់ឈើដែលជំម្រកត្រីនិងប្រភេទសត្វល្អួន ចំនួន ២០០ គល់ឈើ | ចំនួន ២០០ គល់ឈើ នឹងបានដាក់នៅកន្លែងអភិរក្សបឹងក្របីខ្ចក | ៣.៧១០.០០០ | សប្បុរសជន | | |
| ៣.៤.ផលិតផ្ទាំងប៉ាណូផ្សព្វផ្សាយ | • ចំនួន ៤ ស្លាកផ្ទាំងប៉ាណូនឹងបោះសម្រាប់ផ្សព្វផ្សាយ<br>• ផែនទី១ផ្ទាំងត្រូវបានដាក់នៅកន្លែងអភិរក្ស | ៤.២០០.០០០ | | | |
| ៣.៥.ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋពីកន្លែងអភិរក្ស | បង្កើនការយល់ដឹងពីកន្លែងអភិរក្សត្រីមេពូជដល់ប្រជាពលរដ្ឋ | ២០០.០០០ | | | |
| ៣.៦.ចុះល្បាតជាប្រចាំ | បទល្មើសនេសាទនិងមានការថយចុះតាមរយៈការចុះល្បាត | ១.០៨០.០០០ | | | |
| **៤.ការគ្រប់គ្រងព្រៃលិចទឹកសហគមន៍នេសាទ** | • សមាជិកសហគមន៍យល់ដឹងពីសារៈសំខាន់នៃព្រៃលិចទឹក<br>• ព្រៃលិចត្រូវបានការពារដោយសមាជិកសហគមន៍នេសាទ | | | | |
| ៤.១.ប្រជុំផ្សព្វផ្សាយពីសារៈប្រយោជន៍ព្រៃលិចទឹក | សមាជិកសហគមន៍យល់ដឹងពីប្រយោជន៍ និងថែរក្សាព្រៃលិចទឹក | ២០០.០០០ | រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ សប្បុរសជន | ២០១៧ | ២០១៨ |
| ៤.២.ដាំព្រៃលិចទឹកនៅកន្លែងអភិរក្ស វាលព្រៃគ្រែស្មោធំត្បូង ២ **ហត** | • រៀបចំថ្នាលបណ្តុះកូនឈើ<br>• ពិធីដាំកូនឈើ និងដាក់ស្លាកសញ្ញាការពារ ថែរក្សា និងការពារ | ១.០០០.០០០ | | | |
| ៤.៣.ថែរក្សា និងការពារព្រៃលិចទឹក ក្របីខ្ចក **៦៨,២០ ហត** | • ផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធទាំងអស់<br>• ដាក់ស្លាកសញ្ញានាទីព្រៃលិចទឹក | ៥០០.០០០ | | | |
| ៤.៤.ចុះល្បាតជាប្រចាំ | សមាជិកសហគមន៍នេសាទចូលរួមទប់ស្កាត់ការកាប់បំផ្លាញព្រៃលិចទឹក | ១.៥០០.០០០ | | | |
| **៥.ការអភិវឌ្ឍន៍វារីវប្បកម្ម** | •បង្កើនពូជត្រីសម្រាប់ហូបចុកក្នុងមូលដ្ឋាន<br>•រកប្រាក់ចំណូលជួយលើកស្ទួយសេដ្ឋកិច្ចគ្រួសារ<br>•កាត់បន្ថយសម្ពាធនេសាទលើធនធានជលផលហួសកំរិត។ | | | | |
| **៥.១.ការចិញ្ចឹមត្រីដំរីក្នុងចំនួន ៥ គ្រួសារ** | | | | | |
| ៥.១.១.ជ្រើសរើសសមាជិកសហគមន៍នេសាទ | សមាជិកសហគមន៍នេសាទចំនួន ៥ គ្រួសារត្រូវបានជ្រើសរើស | ៣.៨០០.០០០ | រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ សប្បុរសជន | ២០១៧ | ២០១៨ |
| ៥.១.២.បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រីដំរី | ចំនួន ៥ គ្រួសារ នឹងបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រីដំរី | | | | |
| ៥.១.៣.ធ្វើស្រះចិញ្ចឹមត្រីដំរី | ចំនួន ៥ ដែលក្នុង១បៃមានទំហំ ១០ម x ៥ម x ២ម ត្រូវបានធ្វើរួចរាល់ | | | | |
| ៥.១.៤.ការដាក់កូនត្រីក្នុងស្រះ | ចំនួនកូនត្រី ៣០០០កូន/គ្រួសារ នឹងផ្តល់ដល់សមាជិក | | | | |
| ៥.១.៥ ត្រួតពិនិត្យតាមដាន | សមាជិកចំនួន ៥ គ្រួសារ នឹងពិនិត្យជាប្រចាំក្នុងពេលចិញ្ចឹមត្រី | | | | |
| **៥.២.ការចិញ្ចឹមត្រីប្រាក្នុងចំនួន ៧ គ្រួសារ** | | | | | |
| ៥.២.១.ជ្រើសរើសសមាជិកសហគមន៍នេសាទ | សមាជិកសហគមន៍នេសាទចំនួន ៧ គ្រួសារនឹងត្រូវបានជ្រើសរើស | | រាជរដ្ឋាភិបាល | | |

| | | | | | |
|---|---|---|---|---|---|
| ៥.២.២.បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រីប្រា | ចំនួន ៧ គ្រួសារ នឹងបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រីប្រា | ២.៤០០.០០០ | ដៃគូអភិវឌ្ឍន៍<br>សប្បុរសជន | ២០១៨ | ២០១៩ |
| ៥.២.៣.ធ្វើស្រះចិញ្ចឹមត្រីប្រា | ចំនួន ៧ស្រះ ក្នុង១បែមានទំហំ ១០ម X ៥ មX២ម ត្រូវបានធ្វើរួចរាល់ | | | | |
| ៥.២.៤.ការដាក់កូនត្រីក្នុងស្រះ | ចំនួនកូនត្រី ៣,៥០០កូន/គ្រួសារ នឹងផ្តល់ដល់សមាជិកសហគមន៍ | | | | |
| ៥.២.៥ ត្រួតពិនិត្យតាមដាន | សមាជិកចំនួន ៧ គ្រួសារ នឹងធ្វើការពិនិត្យជាប្រចាំក្នុងពេលចិញ្ចឹមត្រី | | | | |
| **៥.៣.ការចិញ្ចឹមត្រីអណ្តែងក្នុងចំនួន ១០ គ្រួសារ** | | | | | |
| ៥.៣.១.ជ្រើសរើសសមាជិកសហគមន៍នេសាទ | សមាជិកសហគមន៍នេសាទចំនួន ១០ គ្រួសារត្រូវបានជ្រើសរើស | ២.៥២០.០០០ | រាជរដ្ឋាភិបាល<br>ដៃគូអភិវឌ្ឍន៍<br>សប្បុរសជន | ២០១៩ | ២០១៩ |
| ៥.៣.២.បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រី | ចំនួន ១០ គ្រួសារ នឹងបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រីអណ្តែង | | | | |
| ៥.៣.៣.ធ្វើស្រះចិញ្ចឹមត្រីអណ្តែង | ចំនួន ១០ ក្នុង១ស្រះមានទំហំ ១០ម X ៥ម X ២ ម ត្រូវបានធ្វើរួចរាល់ | | | | |
| ៥.៣.៤.ការដាក់កូនត្រីក្នុងស្រះ | ចំនួនកូនត្រីអណ្តែង ៣,៥០០កូន/គ្រួសារ នឹងផ្តល់ដល់សមាជិក | | | | |
| ៥.៣.៥ ត្រួតពិនិត្យតាមដាន | សមាជិកចំនួន ១០ គ្រួសារ នឹងធ្វើការពិនិត្យជាប្រចាំក្នុងពេលចិញ្ចឹមត្រី | | | | |
| **៥.៤.ការចិញ្ចឹមត្រីឆ្ពិនក្នុងចំនួន ៦ គ្រួសារ** | | | | | |
| ៥.៤.១.ជ្រើសរើសសមាជិកសហគមន៍នេសាទ | សមាជិកសហគមន៍នេសាទចំនួន ៦ គ្រួសារត្រូវបានជ្រើសរើស | ១.៥០០.០០០ | រាជរដ្ឋាភិបាល<br>ដៃគូអភិវឌ្ឍន៍<br>សប្បុរសជន | ២០២០ | ២០២០ |
| ៥.៤.២.បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រី | ចំនួន ៦ គ្រួសារ នឹងបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រីឆ្ពិន | | | | |
| ៥.៤.៣.ធ្វើស្រះចិញ្ចឹមត្រីឆ្ពិន | ចំនួន ៦ ក្នុង១ស្រះមានទំហំ ១០ម X ៥ម X ២ ម ត្រូវបានធ្វើរួចរាល់ | | | | |
| ៥.៤.៤.ការដាក់កូនត្រីក្នុងស្រះ | ចំនួនកូនត្រីអណ្តែង ៣,៥០០កូន/គ្រួសារ នឹងផ្តល់ដល់សមាជិក | | | | |
| ៥.៤.៥ ត្រួតពិនិត្យតាមដាន | សមាជិកចំនួន ៦ គ្រួសារ នឹងធ្វើការពិនិត្យជាប្រចាំក្នុងពេលចិញ្ចឹមត្រី | | | | |
| **៦.ការអភិវឌ្ឍន៍មុខរបរទ្រទ្រង់ជីវភាព** | • សមាជិកសហគមន៍បង្កើនប្រាក់ចំណូល<br>• ជួយកាត់បន្ថយអត្រាចំណាកស្រុក<br>• សមាជិកយល់ដឹងពីបច្ចេកទេសចិញ្ចឹមសត្វ | | | | |
| **៦.១.សមាជិកសហគមន៍ចិញ្ចឹមមាន់ និងទា** | ចំនួន ៧ គ្រួសារផ្តល់បច្ចេកទេសចិញ្ចឹមមាន់ និងទាជាលក្ខណៈគ្រួសារ | | | | |
| ៦.១.១ ជ្រើសរើសកសិករស្ម័គ្រចិត្ត | សមាជិកសហគមន៍ស្ម័គ្រចិត្តចំនួន ៧ គ្រួសារត្រូវបានជ្រើសរើស | **១.០៥០.០០០** | រាជរដ្ឋាភិបាល<br>ដៃគូអភិវឌ្ឍន៍<br>សប្បុរសជន | ២០១៧ | ២០២០ |
| ៦.១.២ វគ្គបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមមាន់ទា | ចំនួន ៧ គ្រួសារនឹងត្រូវបានបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមមាន់-ទា | | | | |
| ៦.១.៣ ការធ្វើទ្រុងចិញ្ចឹមមាន់ ទា | ចំនួន ៧ ទ្រុង ដែលក្នុង១ទ្រុងមាន ទំហំ ២,៥ម X ៤ ម ត្រូវធ្វើរួចរាល់ | | | | |
| ៦.១.៤ ផ្តល់ពូជ និងសំភារៈ | មាន់ ទាចំនួន ៤២ ក្បាល និងសំភារៈនឹងផ្តល់ដល់សមាជិកស្ម័គ្រចិត្ត | | | | |
| ៦.១.៥ តាមដានត្រួតពិនិត្យ | សមាជិកស្ម័គ្រចិត្ត នឹងធ្វើការត្រួតពិនិត្យជាប្រចាំក្នុងពេលចិញ្ចឹមសត្វ | | | | |

| | | | | | |
|---|---|---|---|---|---|
| **៦.២.សមាជិកសហគមន៍នេសាទចិញ្ចឹមជ្រូក** | ចំនួន ៧គ្រួសារផ្តល់បច្ចេកទេសចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារ | **២.៨០០.០០០** | រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ សប្បុរសជន | ២០១៧ | ២០២០ |
| ៦.២.១ ជ្រើសរើសកសិករស្ម័គ្រចិត្ត | សមាជិកសហគមន៍ស្ម័គ្រចិត្តចំនួន ៧ គ្រួសារត្រូវបានជ្រើសរើស | | | | |
| ៦.២.២ វគ្គបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមជ្រូក | ចំនួន ៧ គ្រួសារ នឹងត្រូវបានបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមជ្រូក | | | | |
| ៦.២.៣ ការធ្វើទ្រុងចិញ្ចឹមជ្រូក | ចំនួន ៧ ទ្រុង ដែលក្នុង១ទ្រុងមាន ទំហំ ២,៥ម X ៤ ម ត្រូវធ្វើរួចរាល់ | | | | |
| ៦.២.៤ ផ្តល់ពូជ និងសំភារៈ | ជ្រូកមានចំនួន ១៤ ក្បាល និងសំភារៈនឹងផ្តល់ដល់សមាជិកស្ម័គ្រចិត្ត | | | | |
| ៦.២.៥ តាមដានត្រួតពិនិត្យ | សមាជិកស្ម័គ្រចិត្ត នឹងធ្វើការត្រួតពិនិត្យជាប្រចាំក្នុងពេលចិញ្ចឹមសត្វ | | | | |
| **៧.ការអភិវឌ្ឍន៍កម្មវិធីចំរុះ** | | | | | |
| ៧.១. បង្កើតក្រុមសន្សំប្រាក់ | សមាជិកសហគមន៍ស្ម័គ្រចិត្ត នឹងចងក្រងជាក្រុមសន្សំប្រាក់ | | | | |
| ៧.១.១ផ្សព្វផ្សាយទស្សនៈដល់ក្រុមសន្សំ | សមាជិកស្ម័គ្រចិត្តចំនួន ២៥ នាក់ នឹងត្រូវបានផ្សព្វផ្សាយទស្សនៈ | **៥.០០០.០០០** | រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ សប្បុរសជន | ២០១៧ | ២០២០ |
| ៧.១.២ ការបង្កើតក្រុមសន្សំ | សមាជិកស្ម័គ្រចិត្តចំនួន ១៥ នាក់ នឹងបានបង្កើតក្រុមសន្សំ | | | | |
| ៧.១.៣ បោះឆ្នោតជ្រើសរើសប្រធាន អនុ ប្រធាន | ប្រធាន អនុ ប្រធាន លេខា និងហិរញ្ញិកនឹងត្រូវបានបោះឆ្នោតជ្រើសរើស | | | | |
| ៧.១.៤ ការបង្កើតលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុង | លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង នឹងត្រូវបានបង្កើតឡើង | | | | |
| ៧.១.៥ ការផ្តល់ទុន និងសំភារៈ | ទុន និងសំភារៈ នឹងត្រូវបានផ្តល់ក្រុមសន្សំប្រាក់ | | | | |
| ៧.១.៦ បណ្តុះបណ្តាលពីការរៀបចំថវិកា-ឯកសារ | សមាជិកចំនួន ១៥នាក់ នឹងបណ្តុះបណ្តាលពីការរៀបចំថវិកានិងឯកសារ | | | | |
| ៧.១.៧ ត្រួតពិនិត្យតាមដាន | ក្រុមសន្សំ នឹងធ្វើការត្រួតពិនិត្យជាប្រចាំក្នុងពេលអនុវត្ត | | | | |
| **៨.ការពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍នេសាទ** | • គណៈកម្មការអនុវត្តសកម្មភាពបានល្អប្រសើរ<br>• យល់ពីតួនាទីនិងភារកិច្ចរបស់ពួកគាត់<br>• បង្កើនសាមគ្គីភាពនិងការទំនាក់ទំនងល្អជាមួយអ្នកពាក់ព័ន្ធ | | | | |
| ៨.១.បណ្តុះបណ្តាលរៀបធ្វើកំណត់ហេតុ សរសេររបាយការណ៍ និងលិខិតរដ្ឋបាល | កំណត់ហេតុ សរសេររបាយការណ៍ និងលិខិតរដ្ឋបាលនឹងត្រូវបានបណ្តុះបណ្តាល | ៤០០.០០០ | រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ សប្បុរសជន | ២០១៨ | ២០១៨ |
| ៨.២.បណ្តុះបណ្តាលការគ្រប់គ្រងថវិកា | ការគ្រប់គ្រងថវិកា នឹងត្រូវបានបណ្តុះបណ្តាល | ៣០០.០០០ | | ២០១៨ | ២០១៨ |
| ៨.៣.បណ្តុះបណ្តាលការដោះស្រាយទំនាស់ | វិធីសាស្ត្រដោះស្រាយទំនាស់នឹងត្រូវបានបណ្តុះបណ្តាល | ៤០០.០០០ | | ២០១៩ | ២០១៩ |
| ៨.៤.បណ្តុះបណ្តាលជំនាញក្នុងការសម្របសម្រួល | ជំនាញសម្របសម្រួលនឹងត្រូវបានបណ្តុះបណ្តាល | ២០០.០០០ | | ២០១៩ | ២០១៩ |
| ៨.៥.បណ្តុះបណ្តាលការរៀបចំផែនការ | ការរៀបចំផែនការ នឹងត្រូវបានបណ្តុះបណ្តាល | ៤០០.០០០ | | ២០២០ | ២០២០ |
| **៩.ផ្សព្វផ្សាយពីច្បាប់ អនុក្រឹត្យ និងលិខិតបទដ្ឋាន** | • បង្កើនការយល់ដឹងដល់ប្រជាពលរដ្ឋ | | | | |

| | | | | | |
|---|---|---|---|---|---|
| **ពាក់ព័ន្ធនឹងវិស័យជលផល** | • កាត់បន្ថយសកម្មភាពបទល្មើសនេសាទ | | | | |
| ៩.១.ផ្សព្វផ្សាយពីច្បាប់ អនុក្រឹត្យ និងលិខិតបទដ្ឋានពាក់ព័ន្ធនឹងវិស័យជលផល | ច្បាប់ អនុក្រឹត្យ និងលិខិតបទដ្ឋានពាក់ព័ន្ធជាមួយវិស័យជលផល នឹងត្រូវបានផ្សព្វផ្សាយដល់សមាជិកសហគមន៍ | ២.០០០.០០០ | | ២០១៧ | ២០២០ |
| ៩.២.ផ្សព្វផ្សាយលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុង | លក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុង នឹងផ្សព្វផ្សាយ | ៧៥០.០០០ | | ២០១៧ | ២០២០ |
| **១០.ជួសជុលស្នាក់ការបណ្តែតទឹកសហគមន៍** | | | | | |
| ១០.១.ជួសជុលផ្នែកខាងក្រោមស្នាក់ការ | ស្នាក់ការបណ្តែតទឹករបស់សហគមន៍នេសាទត្រូវបានជួសជុល | ២៥.០០០.០០០ | | ២០១៧ | ២០២០ |
| ១០.១.តុ កៅអី និងទូឯកសា | សម្ភារៈកៅអី និងទូឯកសារ ត្រូវបានចំពាក់ | ១.០០០.០០០ | | | |
| **១១.ថវិកាសម្រាប់អភិវឌ្ឍន៍សហគមន៍** | | | | | |
| ១១.១.ភាគទានប្រចាំឆ្នាំពីសមាជិកសហគមន៍ | ភាគទានប្រចាំឆ្នាំពីសមាជិកសហគមន៍នេសាទ | ១.៧៥០.០០០ | រាជរដ្ឋាភិបាល<br>គូអភិវឌ្ឍន៍<br>សប្បុរសជន | ២០១៧ | ២០២០ |
| ១១.២.ពីអ្នកនេសាទខាងក្រៅ ឬអ្នកមិនមែនជាសមាជិក | ពីអ្នកនេសាទខាងក្រៅឬអ្នកមិនមែនជាសមាជិក | ៨.២៥០.០០០ | | | |
| ១១.៣.**គម្រោងស្នើសុំ**<br>• បដិភាគពីរាជរដ្ឋាភិបាល<br>• អំណោយពីសប្បុរសជន<br>• អង្គការដៃគូ | បដិភាគពីរាជរដ្ឋាភិបាល សប្បុរសជន និងអង្គការដៃគូអភិវឌ្ឍន៍នានា | ៥.៧៥០.០០០ | | | |
| **១២.ការពង្រឹងបណ្តាញសហគមន៍នេសាទ និង ចូលរួមប្រជុំផ្សេងៗ** | | | | ២០១៧ | ២០២២ |
| ១២.១.ប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍ | ប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍នេសាទនឹងត្រូវបានរៀបចំ | ៨០.០០០ | រាជរដ្ឋាភិបាល<br>គូអភិវឌ្ឍន៍<br>សប្បុរសជន | ២០១៧ | ២០២០ |
| ១២.២.ចូលរួមប្រជុំប្រចាំខែជាមួយក្រុមប្រឹក្សាឃុំ | គណៈកម្មការសហគមន៍នឹងចូលរួមប្រជុំប្រចាំខែជាមួយក្រុមប្រឹក្សាឃុំ | ៨០.០០០ | | ២០១៧ | ២០២០ |
| ១២.៣.ប្រជុំបណ្តាញសហគមន៍នេសាទថ្នាក់ស្រុក | បណ្តាញសហគមន៍នេសាទថ្នាក់ស្រុកនឹងត្រូវបានរៀបចំប្រជុំ | ២០០.០០០ | | ២០១៧ | ២០២០ |
| ១២.៤.ប្រជុំបណ្តាញសហគមន៍នេសាទថ្នាក់ខេត្ត | បណ្តាញសហគមន៍នេសាទថ្នាក់ខេត្តនឹងត្រូវបានរៀបចំប្រជុំ | ៤០០.០០០ | | ២០១៧ | ២០២០ |
| **គម្រោងចំណាយសរុប** | | | | | |

បានឃើញ និង គោរពជូន
លោកនាយខណ្ឌរដ្ឋបាលជលផលកំពង់ធំ
ដើម្បីជូនពិនិត្យ និងសម្រួល
ថ្ងៃទី២១......ខែមីនា ឆ្នាំ២០១៧
**នាយផ្នែករដ្ឋបាលជលផលប្រាសាទសំបូរ**

គូ.ប៊ុនធឿន

បានឃើញ និង គោរពជូន
លោកនាយផ្នែករដ្ឋបាលជលផល
ប្រាសាទសំបូរ
ដើម្បីជូនពិនិត្យ និងសម្រួល
ថ្ងៃទី២១......ខែមីនា ឆ្នាំ២០១៧
**នាយសង្កាត់រដ្ឋបាលជលផលសន្ទុក**

ថិន ភក្ដី

លេខ:..............
បានឃើញ និង គោរពជូន
លោកនាយសង្កាត់រដ្ឋបាលជលផល
សន្ទុក
ដើម្បីជូនពិនិត្យ និងសម្រួល
ថ្ងៃទី.......ខែមីនា ឆ្នាំ២០១៧
**មេឃុំ**

ប៉ែន ឡឿន

សូមគោរពជូន
លោកមេឃុំភ្លៅ
ដើម្បីជូនពិនិត្យ និងសម្រួល
..........ថ្ងៃទី........ខែមីនា ឆ្នាំ២០១៧.
**ប្រធានគណៈកម្មការសហគមន៍នេសាទ**

កើ សុ ឃើន

លេខ:..........
បានឃើញ និង គោរពជូន
លោកប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
ខេត្តកំពង់ធំ
ដើម្បីជូនពិនិត្យ និងសម្រួល
..........កំពង់ធំ ថ្ងៃទី ០៤......ខែមេសា ឆ្នាំ ២០១៧
**នាយខណ្ឌរដ្ឋបាលជលផលកំពង់ធំ**

ប៉ែន_វណ្ណារិទ្ធ

លេខ..........
បានឃើញ និង គោរពជូន
ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា ប្រធានរដ្ឋបាលជលផល
ដើម្បីពិនិត្យ និង សម្រេចដោយអនុគ្រោះ
កំពង់ធំ ថ្ងៃទី១១......ខែមេសា ឆ្នាំ ២០១៧
**ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពង់ធំ**

ធីវ វណ្ណធីរ

លេខ..........
បានឃើញ និងឯកភាព
រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៧
**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**
**ប្រធានរដ្ឋបាលជលផល**

អេង ជាសាន